# ការទទួលខុសត្រូវលើផលិតផល

## ១. សេចក្តីផ្តើម

ការទទួលខុសត្រូវលើផលិតផល ត្រូវបានចែងក្រោមបញ្ញត្តិគោល ស្តីពី ការទទួលខុសត្រូវលើអំពើអនីត្យានុកូលភាព។ ខណៈដែល បញ្ហាផលិតផលមានវិការៈ ឬគ្មានគុណភាព មានកាន់តែច្រើន ការសិក្សាឬខ្លឹមសារនៃការទទួលខុសត្រូវលើផលិតផល មិនត្រូវបានលើកយកមកសរសេរឲ្យបានផុសផលទេ។ បេសកកម្មនៃអត្ថបទនេះ ដើម្បីជួយជាគំនិតបំពេញបន្ថែមលើប្រធានបទ។ វាជាអត្ថបទដំបូង និងទូទៅ ដោយគ្រាន់តែផ្តល់សញ្ញាណមួយចំនួន ពាក់ព័ន្ធនឹងប្រភេទនៃការទទួលខុសត្រូវ បុគ្គលត្រូវទទួលខុសត្រូវ និងជាពិសេស លទ្ធភាពនៃការដោះសារ ដើម្បីឲ្យរួចផុតពីការទទួលខុសត្រូវលើផលិតផល។ អ្នកនិពន្ធ រំពឹងថា អត្ថបទនេះ នឹងជាមូលដ្ឋាន សម្រាប់ការសិក្សារបស់អ្នកស្រាវជ្រាវបន្តបន្ទាប់ទៀត ដែលចាប់អារម្មណ៍នូវការទទួលខុសត្រូវលើអំពើអនីត្យានុកូល។

## ២.ការទទួលខុសត្រូវលើផលិតផល

### ក.អ្វីទៅជាផលិតផល

ពាក្យ "ផលិតផល" ត្រូវបានផ្តល់នូវអត្ថន័យផ្សេងៗ ទៅតាមយុត្តាធិការប្រទេសនីមួយៗ។ វាជាចលនវត្ថុ[1] ឬទំនិញ[2] ដែលជាទូទៅសំដៅវត្ថុ ដែលអាចប៉ះបាន[3] មើលឃើញបាន មានតម្លៃសម្រាប់ចរាចរក្នុងជំនួញ[4] និងត្រូវបានឆ្លងកាត់ការកែឆ្នៃ។[5] ក្នុងន័យនេះហើយ ទើបបានប្រទេសខ្លះ មិនរាប់បញ្ចូលជាផលិតផល នូវវត្ថុធាតុដើមកសិកម្ម។[6] ប្រទេសខ្លះ លុះត្រា វត្ថុមិនរំកិលភ្ជាប់ទៅនឹងវត្ថុផ្សេង ទើបអាចចាត់ថាជាផលិតផល។ ឧទាហរណ៍ ម៉ាស៊ីន ដាក់ចូលក្នុងឡានជាដើម។[7] ពាក់ព័ន្ធនឹងតម្លៃ មិនមានភាពច្បាស់លាស់ទេ ក៏ប៉ុន្តែ អ្វីដែលអាចសន្និដ្ឋានបានថា តម្លៃទាបឬ ខ្ពស់ក៏ដោយ មិនចោទជាបញ្ហាទេ ឲ្យតែផលិត

---

[1] កម្ពុជា មានច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព ទំនិញ និងសេវាកម្ម ឆ្នាំ ២០០១ ក៏ប៉ុន្តែ ច្បាប់នេះ មិនបានផ្តល់ន័យអ្វីទៅជាផលិតផលទេ។

[2] Piotr Machnilowski ed., European Product Liability, An Analysis of the State of the Art in the Era of New Technologies (EU Product Liability) 2016, p.41.

[3] *Id.*, p. 317.

[4] *Id.*, p.150.

[5] *Id.*, p.150; Johns Day, Product Liability in Japan, p. 1, available at untitled (jonesday.com)

[6] *Id.*, p.413.

[7] *Id.*, p.461.

ផលថោកនោះ បង្កហានិភ័យ និងបំពេញនូវធាតុផ្សំដើម្បីទាំឲ្យទទួលខុសត្រូវ អ្នកផលិតនឹងទទួលខុសត្រូវហើយ។

ក្នុងន័យចង្អៀត និងដើម្បីដាក់ឲ្យទទួលខុសត្រូវ ផលិតផល ត្រូវតែបានដាក់ចរាចរក្នុងទីផ្សារ (circulation in market place)។

## ខ. វិការៈ (Defect)

បញ្ហាផលិតផល មានច្រើនប្រភេទ៖ ផលិតផលសុទ្ធ ផលិតផលក្លែងក្លាយ (ម៉ាក) ផលិតផលគ្មានគុណភាព ឬផលិតផលមានវិការៈជាដើម។ គេអាចស្រួលយល់ថា អ្វីទៅផលិតផលគ្មានគុណភាព។ ក្នុងន័យសាមញ្ញ គ្មានគុណភាព មានន័យថា មិនមានលទ្ធផលដូចបំណងនៃផលិតផល។ ឧទាហរណ៍ ថ្នាំសម្រាប់បំបាត់ក្តៅខ្លួន ក្រោយពេលផឹករួច អ្នកជំងឺបាត់ក្តៅខ្លួន។ នោះហើយជាថ្នាំមានគុណភាព ដែលជាទូទៅ គេហៅថាមានប្រសិទ្ធភាព (effective)។ ក្នុងន័យនេះ ធាតុផ្សំនៃថ្នាំ អាចមិនជាចំណោទបញ្ហា ព្រមទាំងបញ្ហាតម្លៃ។

ចុះអ្វីទៅជា ផលិតផលមានវិការៈ។ ជាទូទៅកាលណាគេនិយាយអំពីវិការៈ គេផ្តោតលើ សុវត្ថិភាពនៃផលិតផល។ សូមមើលខ្លឹមសារនៃសេចក្តីដកស្រង់នេះ៖ *ផលិតផល ត្រូវចាត់ថាមានវិការៈ ប្រសិនបើវាមិនផ្តល់នូវសុវត្ថិភាព ដោយពិចារណាលើស្ថានភាពទាំងអស់ ដែលមិនអាចត្រូវបានរំពឹងសមហេតុសមផល ជាពិសេសទាក់ទងនឹង៖ ១. ការបង្ហាញនូវផលិតផល...*។[8] ឧទាហរណ៍ ជាធម្មតា ពូថៅ ដែលត្រូវយកទៅប្រើដើម្បីពុះអុស ត្រូវមានដងរឹងមាំ សមនឹងផ្លែពូថៅ ដើម្បីទាពេលប្រើកុំ ឲ្យបាក់ មានគ្រោះថ្នាក់។ ដូចនេះ ប្រសិនបើពូថៅ មានដងតូច តែផ្លែធំ វាទំនងជាមានវិការៈ មិនសម្រាប់ប្រើពុះអុសទេ តែអាចប្រើក្នុងមុខងារអ្វីផ្សេង។ នេះជាឧទាហរណ៍ មួយស្រួលយល់ ក៏ប៉ុន្តែសម្រាប់ផលិតផលខ្លះ គេត្រូវការអ្នកជំនាញពិនិត្យ ដើម្បីដឹងថា មានវិការៈឬគ្មាន (វិការៈអាថ៌កំបាំង)។ អ្នកស្រាវជ្រាវ បានសំយោគអំពីសញ្ញាណ ឬកត្តាមួយចំនួន ទាញពីយុត្តិសាស្ត្ររបស់តុលាការ ដើម្បីសម្រេចថា ផលិតផលមានវិការៈ ឬគ្មាន។ កត្តានោះមានដូចជា៖ ម៉ាក ការណែនាំ ឬការព្រមាន ភ្ជាប់នឹងផលិតផល ជាដើម។[9] អ្វីដែល ត្រូវចងចាំគឺថា គ្មានផលិត

---

[8] *A product shall be deemed defective if it does not provide the safety which, taking all circumstances into account, may be reasonably expected, in particular with respect to: 1. the presentation of the product....* ,EU Product Liability, *supra* note 2, p.123.

[9] Product Liability under the Consumer Protection Act (Product Liability under CPA), 2020, p.3, [Product liability under the Consumer Protection Act (pinsentmasons.com)]

ផលណា ដែលមិនមានវិការៈទេ[10] វាអាចមានតិចឬច្រើន។ អ្វីសំខាន់ប្រសិន បើអ្នកផលិត ដឹងថាផលិតផលមានវិការៈហើយ តើម្ចាស់ផលិតផលត្រូវធ្វើដូចម្ដេច?

វាទំនងជាមានច្បាប់ឬ លិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលអ្នកនិពន្ធនេះ មិនបានដឹង។ ក៏ប៉ុន្តែតាមអ្វីដែលមានក្នុងក្រមរដ្ឋប្បវេណីថ្មីនៃកម្ពុជា សញ្ញាណនៃទំនិញ ឬវត្ថុមានវិការៈ ត្រូវបានផ្ដល់ក្នុងទំនាក់ទំនងកិច្ចសន្យាលក់។ ខ្លឹមសារវិការៈមានលក្ខណៈទូលាយ៖ *លើកលែងតែគូភាគីបានកំណត់ផ្សេង វត្ថុដែលបានប្រគល់ឱ្យអ្នកទិញមានលក្ខណៈណាមួយដូចខាងក្រោមនេះត្រូវបានចាត់ទុកថាមានវិការៈ៖ ក- វត្ថុនោះមានភាពមិនស្របនឹងចំនួន គុណភាព និងលក្ខណៈដែលបានកំណត់ក្នុងកិច្ចសន្យា។ ខ- វត្ថុនោះមានភាពផ្សេងពីគំរូដែលអ្នកលក់ បានបង្ហាញឱ្យអ្នកទិញមើល ចំពោះចំនួន គុណភាព និងលក្ខណៈ...*។[11]

ខ្លឹមសារនេះ ក៏បានផ្ដោតលើ សុវត្ថិភាពផងដែរ បើគេនិយាយអំពីវិការៈ។ នៅក្នុងកំណត់តា ស្ដីពីមាត្រានៃក្រមរដ្ឋប្បវេណី មាត្រា៧៥១ ស្ដីពី ការទទួលខុសត្រូវលើផលិតផល អ្នកនិពន្ធ ទទួលស្គាល់ថាវិការៈ មិនត្រូវបានផ្ដល់ទេ ហើយបានយោងដល់ក្រមរដ្ឋប្បវេណីរបស់ជប៉ុន ដែលក៏សង្កត់ធ្ងន់លើសុវត្ថិភាពនៃផលិតផលដែរ។[12]

វិការៈកើតមានជាសរុប ៤ដំណាក់កាល ហើយរដ្ឋខ្លះ ទទួលស្គាល់ថាមានតែ៣ដំណាក់កាលទេ។ ដំណាក់កាលរចនា ផលិត ដាក់ចូលទីផ្សារ និង បង្ហាញផលិតផល (presentation)[13]។ ឧទាហរណ៍ខាងលើក្នុងទំព័រ ២ នៃអត្ថបទនេះ និយាយពីពូថៅនោះ គឺជាវិការៈកើតក្នុងអំឡុងពេលរចនា។

## គ. អ្នកទទួលខុសត្រូវ

ពាក់ព័ន្ធនឹងការទទួលខុសត្រូវលើផលិតផលនេះ គេផ្ទុកផ្ដាក់ការទទួលខុសត្រូវលើអ្នកផលិត (producer) ដែលអាចថាជាម្ចាស់នៃផលិតផល។ ទោះបីជាយ៉ាងនេះក្ដី ចាប់តាំងពីមានវត្ថុធាតុដើមរហូតដល់ពេលផលិត បានផលិតផលសម្រេចចុងក្រោយ មានមនុស្សជាច្រើនចូលរួមក្នុងខ្សែសង្វាក់ផលិត មានដូចជា អ្នកវត្ថុគ្រឿងបង្គុំ (component) អ្នករចនា (design) អ្នកផលិត អ្នកបែងចែក (distrib-

---

[10] Marisa Manley, Product Liability: You Are More Exposed Than You Think, 1987, p. 11, at [Product Liability: You're More Exposed Than You Think (hbr.org)]

[11] ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ មាត្រា ៥៣៩។

[12] *វិការៈ សំដៅទៅលើកង្វះនូវសុវត្ថិភាពដែលចាំបាច់ត្រូវមានជាធម្មតាសម្រាប់ផលិតផល ដែលបានផលិតឡើង ដោយគិតពិចារណានូវលក្ខណៈពិសេសនៃផលិតផលនោះ វិធីប្រើផលិតផលនោះដែលអាចត្រូវបានព្យាករបាន ពេលវេលាដែលអ្នកផលិតវត្ថុនោះជាអាទិ៍ បានប្រគល់ផលិតផលនោះ និងស្ថានភាពផ្សេងៗដែលពាក់ព័ន្ធនឹងផលិតផលនោះ* Ministry of Justice, Note on Each Article of Civil Code, Book Five, 2010, p. 189.

[13] EU Product Liability, *supra* note 2, p. 126.

utor) អ្នកលក់ដុំ ឬអ្នកលក់រាយ (retailors)។[14] អ្នកប្រើប្រាស់ ឬទិញវិញ មានអ្នកទិញ ទៅលក់បន្ត និងអ្នកប្រើប្រាស់ចុងក្រោយ (end user)។[15] ក្នុងចំណោមនេះ មនុស្សមួយចំនួន អាចត្រូវបានចាត់ថាជាអ្នកផលិត។ ក្រមរដ្ឋប្បវេណីកម្ពុជា៖ *៣- ក្នុងខ្លឹមសារនៃមាត្រានេះ ចំពោះចលនវត្ថុដែលនាំចូល អ្នកនាំចូលត្រូវចាត់ទុកថាជាផលិតករ។ ៤- ក្នុងខ្លឹមសារនៃមាត្រានេះ បុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករ ឬអ្នកលក់ នៅលើវត្ថុត្រូវ ចាត់ទុកថាជាផលិតករនៃចលនវត្ថុនោះ។*[16]

ចំណែកការទទួលខុសត្រូវ អាចមានការទទួលខុសត្រូវជាបុគ្គល ឬក្នុងឋានៈជាក្រុមហ៊ុន។ ផ្នែកនេះមិនលម្អិតទេ ដោយសារតម្រូវឲ្យមានការស្រាវជ្រាវបន្ថែមទៀត។

ក្រុមហ៊ុន អាចមានក្រុមហ៊ុនមេ (parent company) និងក្រុមហ៊ុនសាខា (subsidiary) ជាដើម។ តើក្នុងលក្ខខណ្ឌអ្វីដែលក្រុមហ៊ុនមេ ទទួលខុសត្រូវលើផលិតផល ចំពោះទង្វើក្រុមហ៊ុនជាសាខា។ តុលាការ នឹងពិនិត្យមើលដំណើរការងាររបស់ក្រុមហ៊ុនទាំងពីរ។ ប្រសិនបើដំណើរការដូចគ្នា នឹងត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនមេ ហើយក្រុមហ៊ុនជាសាខា គ្រាន់តែជាទីតាំងជំនួញទេ ក្រុមហ៊ុនមេ គឺអង្គភាពទទួលខុសត្រូវលើផលិតផល។[17]

ស្រដៀងគ្នានេះដែរ តើអ្នកផលិតគ្រឿងបង្គុំ ឬអ្នកលក់ ត្រូវទទួលខុសត្រូវទេ នៅពេលដែលផលិតផលសម្រេចមានវិការៈ? វាជារឿងមួយដ៏ស្មុគស្មាញ ដោយសារ វាត្រូវបំពេញលក្ខខណ្ឌមួយចំនួនដើម្បីដាក់ឲ្យទទួលខុសត្រូវ។ ជាក់ស្តែង ដើម្បីឲ្យអ្នកលក់ទទួលខុសត្រូវលើផលិតផល ច្បាប់ដាក់លក្ខខណ្ឌមួយចំនួន៖ *ករណីរកមិនឃើញ អ្នកផលិតក្នុងរយៈពេល ៣ខែ*...។[18]

ពាក់ព័ន្ធនឹងថាតើ ភាគីណាសងប៉ុន្មាន ឬមិនសងសោះ វាអាស្រ័យទៅលើចំណែកចូលរួម នាំឲ្យមានវិការៈ ឬការទទួលខុសត្រូវដោយឡែក ឬរួម ដែលនឹងត្រូវបង្ហាញក្នុងផ្នែកខាងក្រោម។

---

[14] What Are Some Defenses to Product Liability?, p. 2, at [Product Liability Defenses | LegalMatch]() (accessed on 17 December 2020).

[15] EU Product Liability, *supra* note 2, p. 295.

[16] ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ មាត្រា ៧៤១។

[17] Marisa Manley, *supra* note 10, p. 7.

[18] *ប្រសិនបើផលិតករ មិនត្រូវបានកំណត់ អ្នកលក់ អ្នកជួល លើកលែងអ្នកឲ្យជួល (lending lessor) ឬអ្នកជួលស្រដៀងគ្នានឹង lending lessor, ឬអ្នកចែកចាយមានវិជ្ជាជីវៈ ត្រូវទទួលខុសត្រូវចំពោះវិការៈ ក្នុងសុវត្ថិភាពនៃផលិតផល ក្នុងលក្ខខណ្ឌដូចជាផលិតករ លុះត្រា គាត់ (អ្នកលក់) កំណត់អ្នកផ្គត់ផ្គង់របស់ខ្លួន ឬអ្នកផលិត ក្នុងអំឡុងពេល៣ខែ ពីថ្ងៃដែលគាត់បានទទួលការជូនដំណឹងនូវការស្នើសុំពីជនរងគ្រោះ*, EU product liability, *supra* note 2, p. 220.

## ឃ. ទម្រង់ ឬប្រភេទនៃការទទួលខុសត្រូវ

ទម្រង់នៃការទទួលខុសត្រូវក្នុងរឿងរដ្ឋប្បវេណី យ៉ាងតិចមានចំនួនបីៈ១.ការទទួលខុសត្រូវកិច្ចសន្យា[19] (contractual liability) សម្រាប់ការបំពានខសន្យាដោយភាគីណាមួយនៃកិច្ចសន្យា។ វាតម្រូវឲ្យមានកិច្ចសន្យាជាមុន ចង្អុលបង្ហាញច្បាស់ពីសិទ្ធិនិងកាតព្វកិច្ចព្រមទាំងភាគី។ ២. ការទទួលខុសត្រូវ ចំពោះអំពីអនីត្យានុកូល (tort liability)[20]។ ភាគី សិទ្ធិ ឬករណីកិច្ច មិនត្រូវបានចែងក្នុងកិច្ចសន្យាទេ។ ការទទួលខុសត្រូវ កើតចេញពីទំនាក់ទំនងក្រៅកិច្ចសន្យា ដែលភាគីម្នាក់បង្ក ឲ្យមានព្យសនកម្ម ដល់ភាគីណាម្នាក់ទៀត ដោយសារការធ្វេសប្រហែស មិនបានគោរពតាមនិយាម ឬស្តង់ដារតម្រូវណាមួយ។ វាមានមូលដ្ឋានពីកាតព្វកិច្ចថែទាំ (duty of care) ក្នុងទំនាក់ទំនងរវាងបុគ្គលពីរនាក់ជាដើម។ ជាក់ស្តែង គ្រូពេទ្យមានកាតព្វកិច្ចប្រភេទនេះ ចំពោះអ្នកជំងឺចូលទៅព្យាបាល ទទួលការព្យាបាលតាមនិយាម ឯកភាពដើម្បីឲ្យអ្នកជំងឺបានធូរស្បើយ។ ផ្ទុយទៅវិញ ប្រសិនបើគ្រូពេទ្យ មិនបានធ្វើតាមបច្ចេកទេសព្យាបាល ដោយធ្វេសប្រហែស ធ្វើឲ្យអ្នកជំងឺមិនធូរស្បើយ ឬឈឺកាន់តែធ្ងន់ ឬ ស្លាប់ ជនរងគ្រោះ អាចប្តឹងទារសំណងតាមទម្រង់ទទួលខុសត្រូវប្រភេទនេះ (fault Based Liability)។ ភាគីរងគ្រោះ ត្រូវបង្ហាញអំពីការធ្វេសប្រហែសរបស់គ្រូពេទ្យ។ ៣. ការទទួលខុសត្រូវតឹងរឹង[21] (strict liability) ដាក់ទៅលើវិស័យចម្បងមួយចំនួន ដូចជាម្ហូប អាហារ ថ្នាំពេទ្យ ឬ បរិស្ថាន។[22] ខុសពីទម្រង់ទី ១ និងទី២ ទម្រង់នេះ ងាយផ្តុកផ្តាក់លើអាជីវករ (អ្នកផលិត) ដោយគ្រាន់តែផលិតផល មានវិការៈ ហើយបង្កឲ្យមានព្យសនកម្ម គឺគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវ ដោយមិនចាំបាច់បង្ហាញថា អ្នកផលិតវត្ថុមានវិការៈ មានចេតនា ឬ ការធ្វេសប្រហែសនោះទេ។

## ង. ការដោះសារ មិនទទួលខុសត្រូវ

ស្រដៀងគ្នានឹងរឿងព្រហ្មទណ្ឌផងដែរ ក្នុងរឿងរដ្ឋប្បវេណី (ការទទួលខុសត្រូវលើផលិតផល) ក៏មានមូលដ្ឋានសម្រាប់ដោះសារឲ្យរួចផុតពីការទទួលខុសត្រូវផងដែរ ដែលមានដោះសាររួចផុតពីការទទួលខុសត្រូវទាំងស្រុង (complete defenses) ឬដោយផ្នែក (partial defense)។ សម្រាប់ប្រទេស

[19] ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ ឧទាហរណ៍ មាត្រា ៤០៨។

[20] ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ មាត្រា ៧៤៣។

[21] នេះជាការបកប្រែ ដោយអ្នកនិពន្ធនេះ។ Marcia Mobilia Boumil and Clifford E. Elias, the Law of Medical Liability in a Nutshell, 1995, p. 230; *Product Lability Law in Japan*, *supra* note 5, p.1

[22] *Id.*

ប្រកាន់ប្រព័ន្ធស៊ីវិលឡ មូលដ្ឋានទាំងនោះ ត្រូវបានចែងក្នុងច្បាប់ (statutory defenses) រីឯប្រទេសកុំម៉ុនឡ មូលដ្ឋានខ្លះមិនមានចែងក្នុងច្បាប់ តែត្រូវបង្កើតឡើងតាមយុត្តិសាស្ត្ររបស់ចៅក្រម (common law defenses)។ ក្រមរដ្ឋប្បវេណីកម្ពុជា ក៏បានចែងផងដែរ ដែលមូលដ្ឋានខ្លះ ទំនងអនុវត្តរួមលើប្រភេទនៃការទទួលខុសត្រូវ ដូចជាការទទួលខុសត្រូវលើទង្វើអនីតិជន ហើយមូលដ្ឋានដោយឡែក ត្រូវបានចែងសម្រាប់ប្រភេទទទួលខុសត្រូវជាក់លាក់នីមួយៗ។[23]

មូលដ្ឋានទាំងអស់ ក៏ត្រូវបានចាត់ទុកជាមូលដ្ឋានរួម ក្នុងន័យថា ច្បាប់រដ្ឋភាគច្រើនទទួលយក និងមូលដ្ឋានបន្ថែមផ្សេងទៀត។

### ង.១. មូលដ្ឋានរួម (common defense)

មូលដ្ឋានទាំងនេះមានដូចជា ការប្រើប្រាស់ដោយបំពានទូវផលិតផល (misuse) ការសន្មត់ទទួលយកហានិយភ័យ (assumption of risk) ការធ្វេសប្រហែសរបស់អ្នកប្រើប្រាស់ (contributory negligence) ការផ្លាស់ប្តូរជាដុំកំភួន (substantial modification) និង development risk។

#### ង.១.១. ការប្រើប្រាស់ដោយបំពាន

វាជាការបំពានរបស់អ្នកប្រើប្រាស់ ដែលប្រើប្រាស់ផលិតផលខុសពីការណែនាំ ស្តីពីរបៀប ប្រើប្រាស់ (usage instruction)។ តាមសេចក្តីណែនាំ កៅអី ត្រូវបានប្រើតែសម្រាប់អង្គុយ ផ្ទុយទៅវិញ អ្នកប្រើប្រាស់ បានយកទៅទ្រាប់ដើម្បីឈរ ធ្វើឲ្យដួលត្រូវរបួស[24]។ ក្នុងករណីនេះ អ្នកផលិតកៅអី មិនទទួលខុសត្រូវទេ។ ទោះបីជាយ៉ាងនេះក្តី យុត្តិសាស្ត្រ បានចែងកំណត់លក្ខខណ្ឌបន្ថែម។ ក្នុងរឿង កៅអីដដែល អ្នកផលិត អាចព្យាករណ៍បានថា អ្នកប្រើប្រាស់អាចយកកៅអីទៅឈរពីលើ នឹងនាំឲ្យគ្រោះថ្នាក់ (foreseeable risk)។[25] ក្នុងន័យនេះ បើអ្នកប្រើប្រាស់ យកកៅអីទ្រាប់នាំឲ្យគ្រោះថ្នាក់ អ្នកផលិតនៅតែទទួលខុសត្រូវ ដោយសារកៅអីមានវិការៈ។[26]

នេះអនុវត្តសម្រាប់ផលិតផលរថយន្តផងដែរ ដែលប្រសិនបើមានគ្រោះថ្នាក់ មានហានិយភ័យខ្ពស់ ហើយអ្នកផលិតដឹងថា អ្នកបើកបរ មាននិន្នាការចង់បើកលឿន អាចបុកគ្នា ទើបក្រុមហ៊ុន ផលិតពោងការពារសុវត្ថិភាព (airbag) និងធ្វើការព្រមានអំពីវិការៈជាយថាហេតុ។[27] អាស្រ័យហេតុ ប្រសិនបើ

---

[23] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៧ មាត្រា ៧៤៥។

[24] Coulter Boechen, Defenses in a Product Liability, p. 5, at. Defenses in a Product Liability Lawsuit | AllLaw (accessed on 17 December 2020).

[25] *Id.*

[26] *Id.*

[27] *Id.*

ប្រើប្រាស់បំពាន ដែលអ្នកផលិតផល មិនអាចព្យាករណ៍បាន អ្នកផលិត នឹងមិនទទួលខុសត្រូវលើផលិត នោះទេ។

ក្នុងរឿងក្តីមួយ ជនរងគ្រោះបានប្តឹងទារសំណងក្រុមហ៊ុនផលិតជី ដោយសារមិនបានដាក់វិធានការ មិនអាចឲ្យពួកភេរវករ យកជីទៅធ្វើជាបង្កំបន្ទុះគ្រាប់បែក ផ្ទុះសម្លាប់សមាជិកគ្រួសារ ជាជនរងគ្រោះរបស់ពួកគេ។ តុលាការបដិសេធ ដោយអះអាងថា វាជាហានីយភ័យមួយ ដែលក្រុមហ៊ុនផលិតជីគីមី មិនអាចព្យាករណ៍បាន។[28]

### ង.១.២. ការសន្មត់ទទួលយកនូវហានីយភ័យ

សេចក្តីណែនាំប្រើប្រាស់ បានចែងពីរបៀបប្រើប្រាស់ ព្រមទាំងព្រមានអំពីគ្រោះថ្នាក់ ឬហានីយភ័យនៃផលិតផល។ អ្នកប្រើប្រាស់ ដឹងថានឹងមានគ្រោះថ្នាក់ដល់ខ្លួន ក៏ប៉ុន្តែគាត់នៅតែប្រើប្រាស់នោះ អ្នកផលិតនឹងមិនទទួលខុសត្រូវទេ។ វាអាចមានករណីដែលជនរងគ្រោះបានដឹងអំពីហានីយភ័យ ក៏ប៉ុន្តែ ហានីយភ័យ ត្រូវបានបង្កដោយអ្នកទីបី (មិនដឹងហានីយភ័យ) អ្នកផលិតនៅតែទទួលខុសត្រូវលើផលិតផលនោះ។ ទោះបីជាយ៉ាងនេះក្តី គេត្រូវបំពេញលក្ខខណ្ឌផ្សេងទៀត ដើម្បីឲ្យអ្នកផលិតទទួលខុសត្រូវ។[29]

### ង.១.៣. ការប្រែប្រួលជាដុំកំភួន

ដូចដែលបានអះអាងខាងលើ ចាប់តាំងពីការផលិតមកដល់ចេញផលិតផលសម្រេច វាត្រូវការចំណាយពេលវេលា ឆ្លងកាត់ដំណាក់កាលជាច្រើន និងមានមនុស្សចូលរួមជាច្រើនផងដែរ។ វិការៈ អាចកើតមានតាំងពីដំបូង ក្នុងដំណាក់កាលរចនាពុម្ពគម្រូ ឬកើតមានក្រោយមក។ ការប្រែប្រួល អាចមានពីរសេណារីយ៉ោ៖ ១. វិការៈ អាចមានក្នុងពេលផលិត ដូចនេះ អ្នកផលិតនឹងទទួលខុសត្រូវ[30]។ ២. វិការៈ អាចកើតមានក្រោយពេលដែលផលិតផលចេញពីការគ្រប់គ្រងរបស់អ្នកផលិត(producer’s control)។ ការប្រែប្រួល កើតនាពេលដឹកជញ្ជូន ដូចជា ការដឹកជញ្ជូនមិនបានល្អ នាំឲ្យផលិតផលក្លាយជាមានវិការៈ។ បន្ថែមពីលើនេះ ផលិតផលខ្លះ ត្រូវបានដឹកជញ្ជូន ក្នុងទម្រង់ជាវត្ថុបង្គុំ ហើយដែលអ្នកទទួលខុសត្រូវក្នុងការតម្លើង ធ្វើខុសបច្ចេកទេស មិនតាមការណែនាំស្តីពីរបៀបតម្លើង នាំឲ្យមានវិការៈ។[31] នេះ វានឹងជួយឲ្យដឹងថា តើអ្នកណាជាអ្នកទទួលខុសត្រូវលើផលិតផល ដែលបង្ករបួស ដោយសារវិការៈ។

---

[28] *Id.*

[29] Coulter Boeschen, *supra* note 24, p.3.

[30] *Id.*, p. 6; Product Liability under CPA, *supra* note 9, pp.6-7.

[31] *Id.*

### ង.១.៤. Development Risk

នៅពេលដែលផលិតផល ត្រូវបានផលិត មានបច្ចេកវិជ្ជា ឬស្តង់ដារសម្រាប់ផលិតនាពេលនោះ។ នាពេលក្រោយមក ផលិតផល បានបង្កព្យសនកម្មដល់អ្នកប្រើប្រាស់។ អ្នកប្រើប្រាស់ មិនអាចយកបច្ចេកវិជ្ជា ឬស្តង់ដារថ្មី សម្រាប់ផលិតផលិតផលដូចគ្នា ដែលអ្នកប្រើប្រាស់កំពុងប្រើ ហើយអះអាងថាមានហានីយភ័យនោះទេ។ ទ្រឹស្តី Development Risk ជួយការពារមិនឲ្យដាក់ការទទួលខុសត្រូវលើអ្នកផលិត ដោយសារ តែមានបច្ចេកវិជ្ជា ឬស្តង់ដារទំនើប។[32] ក្នុងន័យនេះ ការវាយតម្លៃ គឺផ្អែកលើបច្ចេកវិជ្ជានាពេលផលិត។ នេះក៏បង្ហាញដែរនូវការមិនអាចព្យាករណ៍បាន នូវភាពច្បាស់លាស់នៃការអភិវឌ្ឍបច្ចេកវិជ្ជានាពេលអនាគត។ តាមទ្រឹស្តីច្បាប់ បច្ចេកវិជ្ជាថ្មី មិនត្រូវអនុវត្តប្រតិសកម្ម ដល់ការផលិតនៃពេលមុនទេ។ ការការពាររបៀបនេះ ដល់ផលិតករ មិនឲ្យមានភាពអយុត្តិធម៌ដល់ផលិតករ និង មិនរាំងនវានុវត្តថ្មីនៃការផលិតផលិតផល។ ទោះបីជាយ៉ាងនេះក្តី ផលិតករ នឹងមិនរួចផុតពីការទទួលខុសត្រូវទេ ប្រសិនបើគាត់ធ្វេសប្រហែស ផលិត មិនបានគោរពតាមស្តង់ដាបច្ចេកវិជ្ជានាពេលនោះ និងធ្វើឲ្យផលិតផលរបស់ខ្លួនមានវិការៈ។[33]

### ង.១.៥. ការធ្វេសប្រហែសរបស់អ្នកប្រើប្រាស់

ការធ្វេសប្រហែសទីនេះ សំដៅលើការប្រើប្រាស់ ដោយបំពាន ឬមិនខ្វល់សេចក្តីណែនាំអំពីការប្រើប្រាស់។ ការធ្វេសប្រហែសនេះ អាចត្រូវបានប្រៀបធៀបរវាងកំហុសអ្នកប្រើប្រាស់ និងអ្នកផលិត (comparative negligence) ដែលអាចនាំឈានទៅដល់ អ្នកផលិតមិនទទួលខុសត្រូវសោះ។ នេះទំនងក្នុងករណីដែលអ្នកប្រើប្រាស់មានការប្រហែសធ្ងន់ធ្ងរ (gross fault/negligence)។ វាក៏ពាក់ព័ន្ធការប្រើប្រាស់ដោយបំពានផងដែរ។ អ្នកប្រើប្រាស់មានករណីកិច្ច ប្រុងប្រយ័ត្នសមហេតុផល (reason able care) តែគាត់មិនប្រយ័ត្ន (lack of car)។ អ្នកប្រើប្រាស់ (ជាអ្នកជំនាញ) គាត់មិនខ្វល់ ឬមិនមើលនូវសេចក្តីណែនាំ។ ការធ្វេសប្រហែសនេះ ទោះបីជាផលិតផលគ្មានវិការៈ ក៏នៅតែមានហានីយភ័យខ្ពស់ ហើយដែលការធ្វេសប្រហែសនេះ ជាកត្តាកៀកកិតតែមួយនឹងហានីយភ័យ (sole proximate factor)។ លក្ខខណ្ឌនេះតឹងរឹង ទើបធ្វើឲ្យជនរងគ្រោះខ្លួនឯង មិនអាចសុំសំណងពីអ្នកផលិត។[34]

---

[32] Product Liability under the CPA, *supra* note 9, pp.7-8; Jonhs Days, Product Law Worldview, Product Liability in France, *supra* note 5, p. 2.

[33] EU product liability, *supra* note 2, pp. 194-195.

[34] Coulter Boeschen, *supra* note 24, pp. 3-4; what Are Some Defenses, *supra* note 14, p. 1.

ចំណែកកំហុសកម្រិតណា វាអាស្រ័យទៅតាមច្បាប់ ឬយុត្តិសាស្ត្រកំណត់របស់ប្រទេសនីមួយៗ ដែលអាចត្រឹម ៥០ ភាគរយ ឬ ៨០ ភាគរយ ហើយចំណែកនៃសំណង នឹងត្រូវបានគិតតាមសមាមាត្រជាក់ស្តែងនេះ។[35]

**ង.២. មូលដ្ឋានបន្ទាប់បន្សំ**

**ក**. ក្នុងករណីខ្លះ វិការៈកើតមានសារ តែអ្នកផលិតធ្វើតាមការតម្រូវរបស់អាជ្ញាធរ (mandatory rule)។[36] ក្នុងករណីនេះ អ្នកផលិតមិនទទួលខុសត្រូវលើវិការៈទេ។

**ខ**. ដូចក្នុងករណី ការប្រែប្រួលជាដុំកំភួន វិការៈ មិនមានទេក្នុងពេលផលិតផលចេញពីការគ្រប់គ្រងរបស់អ្នកផលិត តែអាចកើតឡើងដោយសារការតម្លើងនាពេលក្រោយ។ ដូចនេះ អ្នកផលិតមិនទទួលខុសត្រូវទេ។ វាមានន័យថា ជាការទទួលខុសត្រូវរបស់អ្នកផ្សេង។

**គ**. ទំនិញ ឬផលិតផលត្រូវបានផលិត ក៏ប៉ុន្តែ មិនសម្រាប់លក់ក្នុងទីផ្សារ ឬ មិនទាន់ត្រូវបានដាក់ក្នុងទីផ្សារ ក៏ប៉ុន្តែ ជាចៃដន្យ ភាគីទីបី ដូចជាចោរ បានលួចយកទៅលក់ ហើយក្រោយពីប្រើប្រាស់ អ្នកទិញរងគ្រោះ ដោយសារផលិតផលមានវិការៈ[37]។ ក្នុងករណីនេះ អ្នកផលិតមិនទទួលខុសត្រូវទេ។

**ឃ**. វត្ថុខ្លះ ត្រូវបានផលិតសម្រាប់មនុស្សមួយប្រភេទប្រើប្រាស់ ដូចដែលមានផ្លាកសញ្ញាភ្ជាប់ជាមួយនឹងផលិតផលបានបង្ហាញ។ ដូចនេះប្រសិនបើអ្នកផ្សេងយកទៅប្រើ និងទទួលរងព្យសនកម្ម អ្នកផលិត ជាទូទៅ មិនទទួលខុសត្រូវទេ។ សេចក្តីណែនាំ ស្តីពី ការប្រើប្រាស់ ត្រូវមានការព្រមាន ដែលតម្រូវឲ្យមានភាពគ្រប់គ្រាន់ និងច្បាស់លាស់ ដែលអ្នកប្រើប្រាស់អាចយល់ដឹងច្បាស់។[38] ប្រសិនបើ អ្នកប្រើប្រាស់មិនគោរពតាមទេ មានព្យសនកម្ម អ្នកផលិត នឹងមិនទទួលខុសត្រូវទេ។ នេះវាពាក់ព័ន្ធនឹងការធ្វេសប្រហែស ក្នុងការប្រើប្រាស់ ឬ ការប្រើប្រាស់ដោយបំពានផងដែរ។

**ង**. ក្នុងកញ្ចប់ផលិតផល មានសំបុត្រធានា អំពីការខូចខាតក្នុងអំឡុងពេលណាមួយ។ ជាមួយគ្នាដែរ ក្នុងករណីខ្លះ មានការអះអាងដោយអ្នកទិញថានឹងមិនប្តឹង (disclaim)។ ទោះបីជាយ៉ាងនេះក្តី វានឹងមិនមានប្រសិទ្ធភាពទេ ប្រសិនបើខ្លឹមសារនោះបំពាននឹងច្បាប់[39]។ អ្នកប្រើប្រាស់មានកាតព្វកិច្ច ក្នុងការជូនដំណឹងអំពីវិការៈ នាពេលប្រើប្រាស់ក្នុងអំឡុងពេលណាមួយ។ ប្រសិនបើមិនមានការជូនដំណឹងដល់អ្នក

---

[35] Product Liability under CPA, *supra* note 9, pp. 5-6.
[36] David G. Owen, product liability in a nutshell, *supra* note 21, p. 422; Coulter Boeschen, *supra* note 24, p.6.
[37] Product Liability under CPA, *supra* note 9, p. 3.
[38] Marisa Manley, *supra* note 10, p. 4.
[39] Product Liability under CPA, *supra* note 9, p.8.

ផលិត ក្នុងអំឡុងពេលកំណត់ ជនរងគ្រោះអស់សិទ្ធិប្តឹង ឬនិយាយដោយប្រយោល អ្នកផលិតមិនទទួលខុសត្រូវទេ។

**ច**. បន្ថែមពីលើនេះ កិច្ចសន្យាអាចជួយការពារ មិនឲ្យទទួលខុសត្រូវ (contract defense)[40]។ អ្នកលក់អាច អះអាងថា ផលិតផល ត្រូវបានគេវេចខ្ចប់បិទត្រា (sealed container) ដូចនេះខ្លួនមិនដឹងអំពីវិការៈ ហើយមិនទទួលខុសត្រូវទេ។[41] អ្នកលក់ ក៏អាចអះអាងថា មិនទទួលខុសត្រូវទេ ពីព្រោះនៅពេលទិញ អ្នកទិញបានពិនិត្យមើលវត្ថុរួចហើយ (product examination) និងមិនឃើញមានវិការៈទេ[42]។ ជាចុងក្រោយក្នុងវិស័យសុខាភិបាល ថ្នាំពេទ្យដែលត្រូវបានផលិត មិនអាចធានាថា មិនមានប្រតិកម្មគ្រប់មនុស្ស គ្រប់វ័យទេ ដូចនេះ អ្នកផលិតថ្នាំនឹងមិនទទួលខុសត្រូវទេ ជាទូទៅ។[43] ក៏ប៉ុន្តែ អ្វីសំខាន់ ត្រូវមានការព្រមាន និងប្រាប់ដឹងជាក់លាក់ ឲ្យច្បាស់អំពីផលវិបាក (side effect)។

### ច. កម្រិតនិងបន្ទុកភស្តុតាង

កម្រិតភស្តុតាង និងបន្ទុកភស្តុតាង មានច្រើនខុសគ្នា ទៅតាមការកំណត់របស់ច្បាប់ ឬតុលាការប្រទេសនីមួយៗ។ អ្វីដែលគេដឹងច្បាស់និងជាទូទៅ គឺថា កម្រិតភស្តុតាង ក្នុងសំណុំរឿងរដ្ឋប្បវេណីគឺតុល្យភាពនៃភាពដែលអាចកើតមានឡើង (balance of probability)[44]។ ជាទូទៅ ក្នុងរឿងក្តីរដ្ឋប្បវេណី អ្នកទាមទារ ឬអះអាង ជាអ្នកមានបន្ទុកភស្តុតាង។ ប្រសិនបើ បុគ្គល *ក* អះអាងថា ភាគីផ្សេងបំពានកិច្ចសន្យា គាត់ត្រូវរកភស្តុតាងបង្ហាញ ថាភាគីចុងចម្លើយ បំពានកិច្ចសន្យា។[45] ក៏ប៉ុន្តែ វាក៏មានករណីលើកលែងផងដែរ អាស្រ័យទៅតាមប្រភេទនៃការទទួលខុសត្រូវ។ ឧទាហរណ៍ ប្រសិនបើវាជាការទទួលខុសត្រូវតឹងរឹង អ្នកផលិត មានបន្ទុកបង្ហាញថា ផលិតផលរបស់ខ្លួនគ្មានវិការៈទេ។ ហេតុអ្វី? ពីព្រោះថាមានតែអ្នកផលិត ដែលដឹង ឬមានលទ្ធភាពក្នុងការបង្ហាញថា ផលិតផល មិនមានវិការៈ[46]។ ពាក់ព័ន្ធនឹងការទទួលខុសត្រូវលើផលិតផលនេះដែរ ជនរងគ្រោះ មិនចាំបាច់បង្ហាញ ធាតុផ្សំអត្តនោម័ត (ចេតនា ឬ

---

[40] *Id.*, p. 8.
[41] *Id.*, p.9.
[42] *Id.*, p. 8.
[43] *Id.*, p. 9.
[44] នេះជាការបកប្រែ ដោយអ្នកនិពន្ធនេះ។ និយាយជាសាមញ្ញ មានន័យថា កម្រិតមាន ៥០ បូក ១ ភាគរយ។ ប្រសិនបើភាគីណាមួយ ក្នុងដំណើរការក្តីដែលភាគី អះអាងអ្វីមួយជាកម្មសិទ្ធិរបស់ខ្លួន ក្នុងពេលវេលាកំណត់ដោយច្បាប់ ឬតុលាការ អាចបង្ហាញភស្តុតាងគាំទ្រ លើសមួយភាគរយ(50 ភាគរយបូក១) ភាគីនោះនឹងឈ្នះការទាមទារ។
[45] Burden of Proof in Latin: *Onus Probandi a Petente*, see Burden of proof (philosophy) - Wikipedia
[46] Coulter Boeschen, *supra* note 24, p. 3.

ការធ្វេសប្រហែសទេ) គាត់គ្រាន់តែបង្ហាញថា ផលិតផល មានវិការៈ ហើយបង្កឲ្យមានគ្រោះថ្នាក់(injury) ដល់គាត់។

## ជ. អាជ្ញាកាលកំណត់សម្រាប់ប្តឹងទាមទារ

មុននឹងនិយាយពីអាជ្ញាយុកាល អ្នកនិពន្ធសូមបញ្ជាក់នូវអត្ថន័យនៃពាក្យ "ផ្អាកអាជ្ញាយុកាលបន្តិច" (repose) ដែលមានក្នុងដំណើរក្តីរដ្ឋប្បវេណី[47]។ នេះក្នុងន័យថា ពេលវេលាសម្រាប់ប្តឹង មិនទាន់មកដល់ទេ លុះត្រាមនុស្សពេញវ័យ អាចមានសិទ្ធិប្តឹងបាន (ករណីអនីតិជន)។ វាស្រដៀងគ្នានឹង ពាក្យ "ផ្អាក" (tolling) ក្នុងរឿងព្រហ្មទណ្ឌ មិនគិតពេលមួយរយៈ ដោយសារកត្តាសង្គ្រាម ដែលយន្តការផ្តល់យុត្តិធម៌មិនដំណើរ ជនរងគ្រោះមិនអាចប្តឹងបាន។[48] នេះជាកត្តាក្រៅ ពីកត្តាពាក់ព័ន្ធនឹងដំណើរការក្តី ដូចជាកិច្ចចោទប្រកាន់ ក្នុងរឿងព្រហ្មទណ្ឌ ដែលអាចបង្អាក់មិនឲ្យពេលវេលាចោទប្រកាន់ដើរ (interruption)។[49]

ក្នុងរឿងរដ្ឋប្បវេណី រយៈពេលអាជ្ញាយុកាលសម្រាប់ប្តឹងទាមទារ ពិតជាមានច្រើន និងស្មុគ្រស្មាញ[50]។ វាពាក់ព័ន្ធទៅតាមវិស័យតូចៗ ដូចជា ប្តឹងទាមទារអចលនៈទ្រព្យ ប្តឹងទាមទារសំណង ក្នុងអំពើអនីត្យានុកូល ការទាមទារសំណងដោយសារការបំពានកិច្ចសន្យា។

ទាក់ទិននឹងការទទួលខុសត្រូវលើផលិតផល រយៈពេលនៃអាជ្ញាយុកាល ក៏មានភាពខុសគ្នា តាមច្បាប់ប្រទេសនីមួយៗដែរ។ ក៏ប៉ុន្តែជាទូទៅ មានពីរកាលបរិច្ឆេទ៖ ១. គិតចាប់ពីថ្ងៃដែលអ្នកប្រើប្រាស់ ដឹងអំពីព្យសនកម្ម និងទី២. ក្រោយពេលដែល អំពើអនីត្យាកុល កើតមានឡើង។ ក្នុងចំណុចនេះ រយៈពេលក៏មានការកំណត់ខុសគ្នាដែរ។ ប្រទេសខ្លះកំណត់ ៥ ឆ្នាំ ក្រោយពីបានដឹងព្យសនកម្ម ហើយក្នុងអំឡុងពេលនេះ ប្រសិនបើមិនមានការប្តឹងទាមទារទេ ជនរងគ្រោះអស់សិទ្ធិទាមទារ។ ដើម្បីឲ្យកាន់តែច្បាស់ សូមពិនិត្យមើលមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជា ដែលត្រូវបានដកស្រង់ទាំងស្រុង៖ *សិទ្ធិទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូល ត្រូវរលត់សិទ្ធិដោយអាជ្ញាយុកាល បើអំឡុងពេល ៣ (បី) ឆ្នាំបានកន្លងហួសបន្ទាប់ពីពេលដែលជនរងគ្រោះ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះ បានដឹងថាអាចទាមទារសំណង ការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬបើអំឡុងពេល ១០ (ដប់) ឆ្នាំបានកន្លងហួស បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង។*[51]

---

[47] Product liability in a nutshell, *supra* note 21, p. 430.

[48] អវតក អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចស្តីពី អញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលបានលើកឡើងដោយមេធាវីការពារក្តី E187, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ para.29.

[49] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ១២៦។

[50] MEAS Bora, Online Sale: Civil and Criminal Liability for Enforcing the Consumer Protection, 2020, p. 5.

[51] មាត្រា ៧៥៦ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧។

### ឈ. ការជួសជុលសំណង

សំណងត្រូវបានធ្វើឡើងចំពោះការខូចខាតលើទ្រព្យសម្បត្តិ ប៉ះពាល់ដល់អាយុជីវិត រាងកាយ កិត្តិយស សិទ្ធិនិងផលប្រយោជន៍។ សំណងមានជាលុយកាក់ (compensation) ឬមិនមែនជាលុយកាក់។ លុយកាក់ សម្រាប់ថ្លៃទ្រព្យសម្បត្តិ ដែលបាត់បង់ ឬបាក់បែក។ ក្រៅពីសំណងជាលុយកាក់ វាអាចជាការស្តារកិត្តិយស តាមរយៈការបញ្ជាឲ្យចារី ចុះក្នុងទំព័រកាសែត កែតម្រូវអត្ថបទបរិហាកេរ្តិ៍ជាដើម។

បន្ថែមពីលើនេះ យុត្តាធិការខ្លះ បានតម្រូវឲ្យសងលើការបាត់បង់ឱកាស (ឡើងតួនាទី) ចំណូលនាពេលអនាគត។ ការពិចារណាលើការជួសជុលសំណង វាអាស្រ័យទៅតាមករណីជាក់ស្តែង ដូចជា ការចូលរួមខុសរបស់ជនរងគ្រោះ វិសាលភាពនៃការខូចខាត ទង្វើរបស់ចារីជាដើម។ ក្នុងករណីខ្លះ សម្រាប់ការមិនអាចជួសជុលជាប្រាក់បាន តុលាការអាចបង្គាប់ឲ្យចារី ធ្វើឬមិនធ្វើអ្វីមួយ ជាការប៉ះប៉ូវចំពោះកំហុស ឬដោះដូរឲ្យនូវវត្ថុថ្មីជំនួស។

ដូចបានអះអាងខាងលើ មានបុគ្គលជាច្រើន នឹងចូលរួមទទួលខុសត្រូវលើផលិតផល។ ពួកគេ ត្រូវចូលរួមសងជាសាមគ្គី (ករណីអ្នកទាំងអស់សមគំនិតប្រព្រឹត្តកំហុស) ឬសងតាមចំណែកខុសរបស់ខ្លួន។ វាអាចមានករណីដែលអ្នកទទួលខុសត្រូវម្នាក់សងសំណងទាំងស្រុងជាមុន និងអាចទាមទារពីអ្នកទទួលខុសត្រូវឲ្យសងតាមក្រោយ តាមសមាមាត្រនៃកំហុសរបស់ពួកគេរៀងៗខ្លួន។

### ៣. សង្ខេប

ការទទួលខុសត្រូវលើផលិតផល មានភាពស្មុគស្មាញ បញ្ហាច្រើនខុសគ្នាៗទៅតាមច្បាប់របស់ប្រទេសនីមួយៗ ពាក់ព័ន្ធនឹងបុគ្គលទទួលខុសត្រូវ ព្រមទាំងការដោះសារជាដើម។ នេះ មិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌលើផលិតផល ដែលអត្ថបទនេះ មិនបានរៀបរាប់បង្ហាញ។ អ្នកនិពន្ធ រំពឹងថា ក្រោយពីបាន អានអត្ថបទនេះរួច អ្នកស្រាវជ្រាវ នឹងបន្តពិនិត្យមើលបញ្ហាជាបន្ថែមទៀត ជាពិសេស ពាក់ព័ន្ធនឹងច្បាប់កម្ពុជា។